ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក

BAMC FINANCE PLC.

# របាយការណ៍

# ប្រចាំឆ្នាំ ២០២០

# មាតិកា


**១ សារប្រធានក្រុមប្រឹក្សាភិបាល** 1

**២ សារអគ្គនាយកប្រតិបត្តិ** 2

**៣ សាវតារគ្រឹះស្ថាន** 3

៣.១ ប្រវត្តិគ្រឹះស្ថាន 3

៣.២ ទស្សនៈវិស័យ 3

៣.៣ បេសកកម្ម 3

៣.៤ តម្លៃស្នូល ប៊ីអេអឹមស៊ី 3

៣.៥ បាវចនា 3

៣.៦ រចនាសម្ព័ន្ធគ្រឹះស្ថាន 4

៣.៧ ភាគទុនិក និងក្រុមប្រឹក្សាភិបាល 5

៣.៨ គណៈគ្រប់គ្រង 6

**៤ លទ្ធផលប្រតិបត្តិការ** 11

៤.១ ប្រតិបត្តិការអាជីវកម្ម 11

៤.២ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ 13

៤.៣ អភិបាលកិច្ចធនធានមនុស្ស 14

៤.៣.១ ព័ត៌មានបុគ្គលិកនិយោជិត 14

៤.៣.២ អត្ថប្រយោជន៍បុគ្គលិកនិយោជិត 14

៤.៣.៣ ការអភិវឌ្ឍបុគ្គលិកនិយោជិត 15

៤.៣.៤ កម្រិតចំណាត់ថ្នាក់មុខតំណែង និងការលើកទឹកចិត្ត 16

៤.៣.៥ អភិក្រមដឹកនាំឆ្នាំ២០២០ និងសិក្ខាបទការងារ ទាំង ១០-ស 17

៤.៣.៦ បទបញ្ជាផ្ទៃក្នុង និងវិធានទោសវិន័យធនធានមនុស្ស 17

៤.៤ សវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង 17

៤.៥ ហានិភ័យ និងអនុលោមភាព 18

៤.៦ គោលនយោបាយ និងនីតិវិធី វិស្សលប្ល៉ូវីង 19

៤.៧ ក្របខ័ណ្ឌការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម 20

៥ សម្រង់របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្មឆ្នាំ២០២០ ....... 20
៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ....... 20
៥.២ របាយការណ៍របស់ស្នងការគណនីឯករាជ្យ ....... 25
៥.៣ តារាងតុល្យការ ....... 28
៥.៤ របាយការណ៍លទ្ធផល ....... 29
៥.៥ របាយការណ៍បម្រែបម្រួលមូលធន ....... 30
៥.៦ របាយការណ៍លំហូរសាច់ប្រាក់ ....... 32

# ១ សារប្រធានក្រុមប្រឹក្សាភិបាល



កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១៩ មានការកើនឡើងជាមធ្យមប្រមាណ ៧,៧% ក្នុងមួយឆ្នាំ ដែលទ្រទ្រង់ដោយវិស័យនាំចេញសំលៀកបំពាក់ និងទេសចរណ៍ ហើយក៏បានបង្ហាញចេញជាសេដ្ឋកិច្ចរីកចម្រើនខ្លាំងមួយ នៅក្នុងពិភពលោក ។ នៅក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជា ត្រូវរងផលប៉ះពាល់ពីការរីករាលដាលជម្ងឺកូវីត១៩ ជាសកល ដែលនាំឲ្យមានការថយចុះជាអវិជ្ជមាន (៣,១%) ដែលជាការធ្លាក់ចុះយ៉ាងគំហុក ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។

ដើម្បីបន្តពង្រឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ក្នុងដំណាក់កាលនៃការរីករាលដាលជម្ងឺកូវីត១៩ ក្នុងប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជា បានបន្តប្តេជ្ញាចិត្តខ្ពស់ ខិតខំក្នុងការតាមដាន និងត្រួតពិនិត្យទៅលើប្រព័ន្ធធនាគារ បរិយាបន្នហិរញ្ញវត្ថុ និងការគាំពារអតិថិជន ស្របតាមការអភិវឌ្ឍក្នុងដំណាក់កាលកំពុងប្រឈមដ៏លំបាកនេះ នៃស្ថានភាពអាជីវកម្ម របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ន។ សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានធ្វើការគណនានៃព័ត៌មានហិរញ្ញវត្ថុបន្ថែម ដោយបានយោងទៅតាមនិយមន័យនៃប្រកាស និងសេចក្តីជូនដំណឹងដែលពាក់ព័ន្ធ ដែលត្រូវបានកំណត់នៅក្នុងកថាខណ្ឌដូចបានបង្ហាញខាងក្រោមនេះ ដែលជាផ្នែកដ៏សំខាន់នៃព័ត៌មានហិរញ្ញវត្ថុបន្ថែម និងគួរត្រូវបានសំដៅរួមគ្នាជាមួយនឹងសេចក្តីសង្ខេប នៃការប្រតិបត្តិតាម ដូចមានខាងក្រោម៖

| | | | |
|---|---|---|---|
| - | អនុបាតសាច់ប្រាក់ងាយស្រួល | ធ៧-០២-៤៨ ប្រ.ក | >១០០% |
| - | ទ្រព្យសកម្មសុទ្ធ ឬមូលនិធិផ្ទាល់សុទ្ធ | ធ៧-០៧-១៣២ ប្រ.ក | ១៤.២០៦.២១០ **ពាន់រៀល** |
| - | អនុបាតសាធនភាព | ធ៧-០២-១៣៣ ប្រ.ក | ៧៧.៩៣% |
| - | ដើមទុនអប្បបរមា | ធ៧-០០-០៦ ប្រ.ក | ១៤.៤០៣.៦៨៣ **ពាន់រៀល** |

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល **ប៊ីអេអឹមស៊ី** ខ្ញុំសូមឆ្លៀតឱកាសថ្លែងអំណរគុណដល់មន្ត្រីទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា និងជាពិសេសអគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលបានផ្តល់ជាការណែនាំ ការគាំទ្រ និងការផ្តល់ជាអនុសាសន៍ល្អៗផ្សេងៗ មកកាន់គ្រឹះស្ថានយើងខ្ញុំ ។

តាំងនាមឱ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកនិយោជិត គ្រប់លំដាប់ថ្នាក់ របស់គ្រឹះស្ថាន ដែលបានបន្តខិតខំប្រឹងប្រែងបំពេញការងារ និងតស៊ូជំនះរាល់គ្រប់ឧបសគ្គ ជាមួយគ្រឹះស្ថាន តាំងពីដើមរៀងមក រហូតមកទល់នឹងពេលនេះ ដោយទទួលបានលទ្ធផលដែលគួរឱ្យកត់សំគាល់មួយនៅក្នុងឆ្នាំនេះ។ ដោយឡែកគ្រឹះស្ថាន នឹងនៅតែបន្តនូវ ទស្សនៈវិស័យ បេសកកម្ម និងប្រើប្រាស់នូវយុទ្ធសាស្ត្រថ្មីៗ ដើម្បីរីកចម្រើនព្រមគ្នា ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការស្វែងរកប្រាក់ចំណេញ ប្រកបដោយតម្លាភាព គណនេយ្យភាព ក្រមសីលធម៌វិជ្ជាជីវៈ គុណធម៌ ការទទួលខុសត្រូវខ្ពស់នៅក្នុងសហគមន៍របស់យើង និងរក្សាឱ្យបាននូវនិរន្តរភាពអាជីវកម្ម នាឆ្នាំបន្តបន្ទាប់ទៅមុខទៀត។

ខ្ញុំសូមថ្លែងអំណរគុណ ជូនចំពោះអតិថិជនទាំងអស់ ដែលបានបន្តដំណើរជាមួយ **ប៊ីអេអឹមស៊ី** ក្នុងន័យបង្កើតផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ក្នុងនាមជា **ដៃគូអាជីវកម្មជាទីទុកចិត្ត គឺ ប៊ីអេអឹមស៊ី**។

ជាចុងក្រោយចំពោះសមិទ្ធិផលរបស់ **ប៊ីអេអឹមស៊ី** ក្នុងឆ្នាំ ២០២០ នេះ គឺពិតជាបានមកពីការចូលរួមចំណែកគាំទ្រយ៉ាងសំខាន់ របស់ធនាគារជាតិនៃកម្ពុជា ការប្តេជ្ញាចិត្តខ្ពស់របស់សមាជិកក្នុងក្រុមគ្រួសារ **ប៊ីអេអឹមស៊ី** និងជាពិសេសអតិថិជនដែលមានភក្តីភាព របស់ **ប៊ីអេអឹមស៊ី** ទាំងអស់។ សូមអរគុណ និងថ្លែងអំណរគុណជាអនេកប្បការ។

**លោកហ៊ុន ពេជ្រ (ប្រធានក្រុមប្រឹក្សាភិបាល)**

# ២ សារអគ្គនាយកប្រតិបត្តិ



សូមសួស្តីឆ្នាំ ២០២០! ខ្ញុំបាទឈ្មោះ KANG DONG HYUN ជាអគ្គនាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក**។ សមាជិកក្នុងក្រុមគ្រួសារ **ប៊ីអេអឹមស៊ី** របស់យើង បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងវិស័យសេដ្ឋកិច្ចជាតិកម្ពុជា ដែលកំពុងប្រឈមនឹងការលំបាកខ្លាំង ក្នុងឆ្នាំ២០២០ ។ ក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទានជាន់ខ្ពស់ និងបានខិតខំប្រឹងប្រែងយ៉ាងសកម្ម នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ និងសុខុមាលភាព រស់នៅរបស់ប្រជាជនទូទៅ នៅក្នុងប្រទេសកម្ពុជា។

ជាមួយនឹងបទពិសោធន៍ដ៏យូរលង់របស់យើង ក្នុងវិស័យហិរញ្ញវត្ថុ និងការយល់ដឹងខ្ពស់ ពីបច្ចេកទេសដ៏ជឿនលឿនដូចពេលបច្ចុប្បន្ន យើងបានខិតខំប្រឹងប្រែងផ្តល់ឱ្យប្រជាជនកម្ពុជានូវ ស្ថិរភាពហិរញ្ញវត្ថុ ការកាត់បន្ថយនូវភាពក្រីក្រ និងការផ្តល់ជាមូលនិធិសង្គ្រោះបន្ទាន់ជាចាំបាច់សម្រាប់អាជីវកម្ម និងការគិតពិចារណាខ្ពស់ ពីភាពងាយស្រួល និងការបម្រើសេវាកម្មល្អ ដល់អតិថិជនរបស់យើងជាអាទិភាពកំពូល។

យើងនឹងបង្កើតឱ្យមានវប្បធម៌ហិរញ្ញវត្ថុ ឈ្នះ-ឈ្នះ តាមរយៈការផ្តល់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ឆ្ពោះទៅរកមនុស្សជាទីស្រឡាញ់ និងជាដៃគូអាជីវកម្មដ៏គួរជាទីទុកចិត្ត ពីសំណាក់អតិថិជនគ្រប់លំដាប់ថ្នាក់។

យើងចង់កសាងឱ្យបាននូវការគ្រប់គ្រង និងការច្នៃប្រឌិតដ៏ល្អមួយ ប្រកបដោយនិរន្តរភាព ដែលនឹងនាំមកនូវសុភមង្គល និងការអភិវឌ្ឍ ដល់អតិថិជនរបស់យើង។ ផ្អែកលើបញ្ហានេះ យើងនឹងគិតអំពីអ្វីដែលយើងអាចធ្វើបានសម្រាប់ការចូលរួមចំណែក និងការអភិវឌ្ឍសង្គមរបស់យើង ហើយយើងនឹងចាប់ផ្តើមអនុវត្តវា។

វប្បធម៌របស់យើងដែលផ្តល់តម្លៃដល់អតិថិជនជាអាទិភាពទីមួយ មិនមែនគ្រាន់តែដើម្បីជួបអតិថិជនក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុប៉ុណ្ណោះនោះទេ ប៉ុន្តែយើង គឺបានគិតអំពីភាពរីកលូតលាស់នៃក្រុមគ្រួសារ មិត្តល្អ និងភាពជាដៃគូអាជីវកម្មដែលគួរជាទីទុកចិត្ត អាចពឹងផ្អែកលើគ្នា និងប្រាស្រ័យទាក់ទងគ្នាបានល្អ។

យើងនឹងខិតខំប្រឹងប្រែង និងផ្តល់ការគាំទ្រដល់អតិថិជននិងក្រុមគ្រួសាររបស់យើង រហូតដល់ថ្ងៃដែលអ្នកពេញចិត្ត ហើយយើងនឹងចូលរួមវិភាគទានឱ្យបានច្រើន ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រុមគ្រួសារ និងអតិថិជនទាំងអស់របស់ **ប៊ីអេអឹមស៊ី** ហើយយើងសន្យាថានឹងនៅតែជាក្រុមគ្រួសារតែមួយ ជាមួយអតិថិជនរបស់យើង ដើម្បីទទួលបានជីវិតកាន់តែល្អប្រសើរឡើង ស្របតាមបាវចនាផ្ទៃក្នុងរបស់យើងថា (**ប៊ីអេអឹមស៊ី**! សម្រាប់ក្រុមគ្រួសារ, **ប៊ីអេអឹមស៊ី**! ល្អដាច់គេ) ។

**សូមអរគុណច្រើន ☺**




**លោក KANG DONG HYUN**

**អគ្គនាយកប្រតិបត្តិ**

# ៣ សាវតាគ្រឹះស្ថាន

## ៣.១ ប្រវត្តិគ្រឹះស្ថាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** គឺជានាមករណ៍ថ្មី ដែលបានផ្លាស់ប្តូរមកពីនាមករណ៍ចាស់ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី** ត្រូវបានបង្កើតឡើង ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដោយទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ **MOC-20937940 ពណ.ចបព** និងមានអត្តលេខក្រុមហ៊ុន **០០០០៨៣៤៧** នៅកាលបរិច្ឆេទចុះបញ្ជីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ។ គ្រឹះស្ថានក៏បានទទួល អាជ្ញាបណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លេខ **ម.ហ-៤៥** មានឈ្មោះ [**ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក**] ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

**សកម្មភាពចម្បងគ្រឹះស្ថាន** គឺផ្តល់នូវសេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលប្រកបដោយស្ថិរភាពចំពោះសហគ្រាសធុនតូច និងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាព អាជីវកម្មចម្បងរបស់គ្រឹះស្ថាន ក្នុងកំឡុងការិយបរិច្ឆេទនេះទេ ។

**សកម្មភាពធុរកិច្ចគ្រឹះស្ថាន** បច្ចុប្បន្នកំពុងពង្រីកប្រតិបត្តិការសេវាហិរញ្ញវត្ថុ ទៅតាមបណ្តា រាជធានី / ខេត្ត / ក្រុង / ស្រុក ដើម្បីផ្តល់នូវភាពងាយស្រួលជូនអតិថិជនដែលមានតម្រូវការឥណទាន ក្នុងគោលបំណងទ្រទ្រង់ សេដ្ឋកិច្ចគ្រួសារ ឧត្តរជីវិតអាជីវកម្ម ការវិនិយោគផ្ទាល់ខ្លួន និងការសង្គ្រោះបន្ទាន់រយៈពេលខ្លី ។

## ៣.២ ទស្សនៈវិស័យ

**"ជាធនាគារវិកល្អឆ្នើមបំផុត សម្រាប់ក្រុមគ្រួសារទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា"**

## ៣.៣ បេសកកម្ម

**"កសាងវិបុលភាពល្អប្រសើរបំផុត សម្រាប់សហគមន៍យើងទាំងអស់គ្នា"**

## ៣.៤ គម្លៃស្នូល ប៊ីអេអឹមស៊ី

- **សេវាកម្មល្អឆ្នើមបំផុត** ៖ យើងតែងតែផ្តល់សេវាកម្មឱ្យលើសការរំពឹងទុករបស់អតិថិជន ។
- **ងាយស្រួលទំនាក់ទំនង** ៖ យើងតែងតែនៅជាមួយអតិថិជនរបស់យើង ។
- **សីលធម៌** ៖ យើងតែងតែគោរពឱ្យតម្លៃអតិថិជនរបស់យើង ។
- **អតិថិជន** ៖ យើងតែងតែបម្រើសេវាកម្មដល់អតិថិជនរបស់យើង ដោយអស់ពីចិត្ត និងបេះដូង ។

## ៣.៥ បាវចនា

**៣.៥.១ បាវចនាខាងក្រៅ "ដៃគូអាជីវកម្មជាទីទុកចិត្តរបស់លោកអ្នក គឺ ប៊ីអេអឹមស៊ី"**

**៣.៥.២ បាវចនាខាងក្នុង " ប៊ីអេអឹមស៊ី! សម្រាប់ក្រុមគ្រួសារ, ប៊ីអេអឹមស៊ី! ល្អដាច់គេ "**

## ៣.៦ រចនាសម្ព័ន្ធគ្រឹះស្ថាន




**កំណត់សម្គាល់ ៖** ន. ( នាយកដ្ឋាន )

## ៣.៧ ភាគទុនិក និងក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ត្រូវបានបង្កើតឡើងដោយ ភាគទុនិកចំនួន ០២ រូប ដែលជានីតិបុគ្គល និងរូបវន្តបុគ្គល ។ ជាមួយគ្នានោះដែរ គ្រឹះស្ថានក៏មានក្រុមប្រឹក្សាភិបាល ចំនួន ០៥ រូប ដែលជាសមាជិកក្នុងពេលបច្ចុប្បន្ន ដោយមាន ០២ រូប ជាភាគទុនិក ដោយត្រូវបានអនុម័ត និងទទួលស្គាល់ពី ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ទាំង ០៥ រូប ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។ ខាងក្រោមនេះ គឺជាបណ្តាភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នាពេលបច្ចុប្បន្ន៖

| **ភាគទុនិក** | **ភាគរយនៃភាគហ៊ុន** |
|---|---|
| ១. ក្រុមហ៊ុន **ភីណាត់ ខេមបូ ខបភើរេសិន** តំណាងដោយ លោក **ហ៊ុន ពេជ្រ** | ៩៧.៨១ % |
| ២. លោក KANG DONG HYUN ជាជនជាតិកូរ៉េខាងត្បូង | ២.១៩ % |

| **ក្រុមប្រឹក្សាភិបាល** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក **ហ៊ុន ពេជ្រ** | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោក KANG DONG HYUN | អភិបាល និងជាអគ្គនាយកប្រតិបត្តិ |
| ៣. លោក **ថុង សុជាត** | អភិបាល និងជានាយកប្រតិបត្តិ |
| ៤. លោក PARK BYUNG KWON | អភិបាល (សវនកម្មផ្ទៃក្នុង) |
| ៥. លោក KIM CHUL WOONG | អភិបាលឯករាជ្យ |

### គណៈកម្មការក្រុមប្រឹក្សាភិបាល៖

| **គណៈកម្មការសវនកម្ម** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក PARK BYUNG KWON | ប្រធានគណៈកម្មការ |
| ២. លោក **ភិន ណារ៉ា** | នាយក នាយកដ្ឋានហិរញ្ញវត្ថុ និងជាសមាជិក |
| ៣. លោក **ប៊ូ សុធារ៉ា** | មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ និងជាសមាជិក |

| **គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក KIM CHUL WOONG | ប្រធានគណៈកម្មការ |
| ២. លោក **សោម ពុទ្ធារ៉ា** | នាយក នាយកដ្ឋានហានិភ័យ & ប្រតិបត្តិតាម និងជាសមាជិក |
| ៣. លោក **ខុម រតនៈ** | មន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ និងជាសមាជិក |

## ៣.៨ គណៈគ្រប់គ្រង



### អគ្គនាយកប្រតិបត្តិ និងជាអភិបាល

លោក Kang Dong Hyun ជាជនជាតិកូរ៉េខាងត្បូង និងជាអគ្គនាយកប្រតិបត្តិ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ក្នុងកំឡុងដើមឆ្នាំ ២០១៩ ។ មុននឹងមកកាន់មុខតំណែងនេះ លោកធ្លាប់ត្រូវបានគេជ្រើសរើស ឱ្យធ្វើជានាយកប្រតិបត្តិ នៅធនាគារភ្នំពេញពាណិជ្ជកម្មជា កំឡុងឆ្នាំ២០១៣ មកដល់ ២០១៨ ។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុសាជីវកម្ម នៅប្រទេសកូរ៉េ ។ ទន្ទឹមនឹងនេះដែរ ក្នុងតួនាទីភាពជាអ្នកដឹកនាំ លោកក៏បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍ ដល់វិស័យធនាគារ និងហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



### នាយកប្រតិបត្តិ និងជាអភិបាល

លោក **ថុង សុជាត** ជាជនជាតិខ្មែរ និងជានាយកប្រតិបត្តិ បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្តាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០១ ។ លោកមានបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុរយៈពេលជាង ១៧ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ ប្រធានផ្នែក ប្រធានគ្រប់គ្រងឥណទានសហគ្រាសខ្នាតតូច និងមធ្យម នាយកសាខា ប្រធានគ្រប់គ្រងឥណទានជាន់ខ្ពស់ និងអ្នកគ្រប់គ្រងទូទៅ ដែលធ្លាប់បម្រើការនៅ ធនាគារ Mekong ធនាគារ ANZ Royal ធនាគារ May Bank ធនាគារ Phnom Penh Commercial និងក្រុមហ៊ុន Miller Drilling Company Limited ។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅដើមឆ្នាំ ២០១៩ ដោយមានតួនាទី និងមុខតំណែង ជានាយកប្រតិបត្តិ របស់គ្រឹះស្ថាន ដើម្បីកែលំអការគ្រប់គ្រងផ្ទៃក្នុងនិងអភិបាលកិច្ចល្អ នៅកន្លែងធ្វើការ ក្នុងព្រះរាជាណាចក្រកម្ពុជា ។



## នាយក នាយកដ្ឋានមុខងារប្រតិបត្តិតាម និងហានិភ័យ និងជាសមាជិក នៃគណៈកម្មការប្រតិបត្តិតាម និងហានិភ័យ

លោក **សោម ពុទ្ធារ៉ា** ជាជនជាតិខ្មែរ និងជានាយក នាយកដ្ឋានមុខងារប្រតិបត្តិតាម និងហានិភ័យ បច្ចុប្បន្ន លោកកំពុង បម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែនម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រងក្នុងឆ្នាំ ២០០៨ និងបរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០៤ ។ លោកធ្លាប់មានបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុរយៈពេលជាង ១៧ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ ភ្នាក់ងារឥណទាន ភ្នាក់ងារដោះស្រាយបំណុល ភ្នាក់ងារទីផ្សារ ប្រធានភ្នាក់ងារទីផ្សារធនាគារអេស៊ីលីដា ភីអិលស៊ី នាយកសាខាធនាគារមេយប៊ែង និងជានាយកសាខាជាន់ខ្ពស់ធនាគារភ្នំពេញពាណិជ្ជ និងត្រូវបានអនុញ្ញាតតែងតាំងជា ប្រធានមុខងារប្រតិបត្តិតាម ដែលទទួលស្គាល់ដោយ អគ្គនាយកដ្ឋានត្រួតពិនិត្យ នៃធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ។ ទន្ទឹមនឹងនេះដែរ យោងលើតួនាទីបច្ចុប្បន្ន លោកតែងតែដឹកនាំ គ្រឹះស្ថាន និងនិយោជិតទាំងអស់ ប្រតិបត្តិតាម គោលនយោបាយ និងនីតិវិធីនានា របស់គ្រឹះស្ថាន ក៏ដូចជាអនុលោមភាព តាមប្រកាស ពីអាជ្ញាធរអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងរួមទាំង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។



## នាយក នាយកដ្ឋានហិរញ្ញវត្ថុ និងជាសមាជិកនៃគណៈកម្មការសវនកម្ម

លោក **ភិន ណារ៉ា** នាយកនាយកដ្ឋានហិរញ្ញវត្ថុ បច្ចុប្បន្ន លោកកំពុងបម្រើការងារនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ ជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០១៥ និងថ្នាក់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រងក្នុងឆ្នាំ២០០៤ ។ លោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈជាច្រើនទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ហើយលោកមាន បទពិសោធន៍ការងារជាង ១៥ឆ្នាំ លើការងារផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ ក្នុងមុខតំណែងចាប់ពីធារី (Teller) រហូតដល់ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ដោយធ្លាប់ធ្វើការនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ។ លោកបានចូលបម្រើការងារ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ចាប់ពីខែធ្នូ ឆ្នាំ២០១៨ ក្នុងមុខតំណែងជា នាយក នាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីអនុវត្តការងាររដោយអនុលោមទៅតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូចនិងមធ្យម ហៅកាត់ថា ("**ស.រ.ហ.អ.ក.ស.ធ.ត.ម**") ក៏ដូចជា អនុលោមភាព តាមប្រកាស ពីអាជ្ញាធរអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងរួមទាំង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។



## នាយក នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

លោក **សុខ ស៊ីថន** នាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បច្ចុប្បន្ន លោកកំពុងបម្រើការងារនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យា និងថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ ២០០២ ។

លោកធ្លាប់មានបទពិសោធន៍ក្នុងវិស័យអប់រំ និងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ១១ ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ សាស្ត្រាចារ្យ និងជានាយករងដេប៉ាតេម៉ង់សាកលវិទ្យាល័យន័រតុន សាស្ត្រាចារ្យសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រធានផ្នែក និងជាប្រធានការិយាល័យក្រុមហ៊ុនប្រេងឥន្ធនៈ ។ លោកបានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅឆ្នាំ២០១៩ ដោយមានតួនាទី និងមុខតំណែង ជានាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីជានាដល់សុវត្ថិភាព នៃប្រព័ន្ធធនាគារស្នូល គ្រឹះស្ថាន ។



## នាយក នាយកដ្ឋានប្រតិបត្តិការស្ដីទី

លោក **នឿក សាវ៉េត** នាយក នាយកដ្ឋានប្រតិបត្តិការស្តីទី បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យធនធានមនុស្ស (HRU) ក្នុងឆ្នាំ ២០១១ ។

លោកធ្លាប់មានបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ១១ ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ មន្ត្រីឥណទាន ប្រធានឥណទាន នាយករងសាខា នាយកសាខា និងប្រធានផ្នែកសវនកម្មផ្ទៃក្នុង ដែលធ្លាប់បម្រើការងារនៅ ប្រតិបត្តិករឥណទានជនបទលីដាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខេមា និងអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាកា ។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅឆ្នាំ២០១៤ ដោយមានតួនាទី និងមុខតំណែង ជានាយកនាយកដ្ឋានប្រតិបត្តិការស្តីទី របស់គ្រឹះស្ថាន។ ទន្ទឹមនឹងនេះដែរ លោកក៏ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាល ជំនាញសវនកម្ម ជំនាញឥណទាន និងព្រមទាំងមានបទពិសោធន៍ និងចំណេះដឹង យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងបណ្តុះបណ្តាលបុគ្គលិក ក្នុងផ្នែកប្រតិបត្តិការអាជីវកម្ម និងជួយជម្រុញឱ្យគ្រឹះស្ថានមានភាពរីកចម្រើន និងទទួលបាននូវប្រាក់ចំណេញ។



## នាយក នាយកដ្ឋានទីផ្សារស្ដីទី

លោក **ហាប់ សុផិត** នាយក នាយកដ្ឋានទីផ្សារស្ដីទី បច្ចុប្បន្ន លោកកំពុងបម្រើការងារនៅការិយាល័យកណ្ដាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ធនាគារ និងហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០១០ និងថ្នាក់បរិញ្ញាបត្រ អភិវឌ្ឍសេដ្ឋកិច្ច ក្នុងឆ្នាំ ២០០០ ។

លោកមានបទពិសោធន៍នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ២១ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ភ្នាក់ងារឥណទាន ភ្នាក់ងារដោះស្រាយបំណុល ធារី (Teller) មន្ត្រីគ្រប់គ្រងសាច់ប្រាក់ក្នុងទូដែក ប្រធានគ្រប់គ្រងសាច់ប្រាក់ក្នុងទូដែក ប្រធានផ្នែកលក់ អ្នកសម្របសម្រួលម៉ាកសកម្មនៃនាយកដ្ឋានទីផ្សារ និងប្រធានផ្នែកលក់ និងទីផ្សារ ដែលធ្លាប់បម្រើការងារនៅ ធនាគារអេស៊ីលីដា ក្រុមហ៊ុន (JTI) ក្រុមហ៊ុន (PSK Group) និងក្រុមហ៊ុន (ADOPEN Cambodia) ។ លោកចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅឆ្នាំ២០១៩ ដោយមានតួនាទី និងមុខតំណែង ជានាយក នាយកដ្ឋានទីផ្សារស្ដីទី ដើម្បីកសាងកិត្តិនាម និងម៉ាកសញ្ញា **ប៊ីអេអឹមស៊ី** ឱ្យល្បីល្បាញ ជាសាធារណៈ។



## មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ និងជាសមាជិកនៃគណៈកម្មការសវនកម្ម

លោក **បូ សុធារ៉ា** មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្ដាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៤ ។

លោកមានធ្លាប់បទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ០៧ ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ មន្ត្រីឥណទាន មន្ត្រីសវនករការិយាល័យកណ្ដាល និងមន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ដែលធ្លាប់បម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិរន្ទន៍ និងអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាកា ។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅឆ្នាំ២០១៤ ដោយមានតួនាទី និងមុខតំណែង ជាមន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ របស់គ្រឹះស្ថាន ។ ទន្ទឹមនឹងនេះដែរ លោកក៏ធ្លាប់បានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើន លើជំនាញសវនកម្ម ជំនាញឥណទាន និងព្រមទាំងមានបទពិសោធន៍ ចំណេះដឹង និងជំនាញ យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងចូលរួមបណ្ដុះបណ្ដាលបុគ្គលិក ក្នុងផ្នែកសវនកម្ម ប្រតិបត្តិការ និងផ្នែកផ្សេងៗទៀត ក្នុងការជួយជម្រុញឱ្យគ្រឹះស្ថានជៀសវាងពីហានិភ័យប្រតិបត្តិការ និងសក្ដានុពល នៃហានិភ័យផ្សេងៗទៀត ។



### មន្ត្រីធនធានមនុស្ស និងរដ្ឋបាលជាន់ខ្ពស់ និងជាសមាជិកគណៈកម្មការធនធានមនុស្ស

លោក **ភេម សេងហ៊ត់** មន្ត្រីធនធានមនុស្ស និងរដ្ឋបាល បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានសហប្រតិបត្តការអន្តរជាតិ កម្ពុជា ក្នុងឆ្នាំ២០១៨ ។ លោកមានបទពិសោធន៍ក្នុងវិស័យអប់រំ និងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ០៥ឆ្នាំ ដែលមានមុខតំណែង ដូចជា បុគ្គលិកការិយាល័យ មន្ត្រីឥណទាន មន្ត្រីរដ្ឋបាល ដែលធ្លាប់បម្រើការងារនៅ អង្គការសហប្រតិបត្តការអន្តរជាតិកម្ពុជា និងអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាកា។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដែលជានាមករណ៍ថ្មី បានផ្លាស់ប្តូរមកពី តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី នៅឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន ដោយមានតួនាទី និងមុខតំណែង ជាមន្ត្រីធនធានមនុស្ស និងរដ្ឋបាល របស់គ្រឹះស្ថាន ។ ទន្ទឹមនឹងនេះដែរ លោកក៏ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាល ជំនាញធនធានមនុស្ស ជំនាញរដ្ឋបាល និងព្រមទាំងមាន បទពិសោធន៍ ចំណេះដឹង និងជំនាញវិជ្ជាជីវៈ យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងបណ្តុះបណ្តាលបុគ្គលិក ក្នុងផ្នែកធនធានមនុស្ស រដ្ឋបាល និងផ្នែកផ្សេងៗទៀត ក្នុងការជួយជ្រោមជ្រែង មូលធនធនធានមនុស្សរបស់គ្រឹះស្ថាន ក្លាយជាធនាគារិកដ៏ល្អឆ្នើមបំផុត ក្នុងព្រះរាជាណាចក្រកម្ពុជា ។



### មន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ និងជាសមាជិកនៃគណៈកម្មការប្រតិបត្តិតាម និងហានិភ័យ

លោក **ខុម រតនៈ** មន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ បច្ចុប្បន្ន លោកកំពុងបម្រើការងារនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) ក្នុងឆ្នាំ២០១៨ ។ លោកធ្លាប់មានបទពិសោធន៍ក្នុងផ្នែកសប្បុរសធម៌អន្តរជាតិ និងក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ០៧ឆ្នាំ ដែលមានមុខតំណែង ដូចជា៖ យុវជនស្ម័គ្រចិត្ត លើផ្នែកសប្បុរសធម៌ មន្ត្រីឥណទាន មន្ត្រីសវនករផ្ទៃក្នុង និងមន្ត្រីប្រតិបត្តិតាម ដែលទទួលស្គាល់ដោយ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដោយធ្លាប់បម្រើការងារនៅ អង្គការសប្បុរសធម៌អន្តរជាតិសែសហ្វី ប្រតិបត្តិករឥណទានជនបទលីដា និងអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាកា ។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** នៅដើមឆ្នាំ២០១៦ ដោយមានតួនាទី និងមុខតំណែង ជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ នាពេលបច្ចុប្បន្ន ។ ទន្ទឹមនឹងនេះផងដែរ ដោយយោងទៅលើតួនាទីរបស់លោកនាពេលបច្ចុប្បន្ន លោក គឺជាបុគ្គលរាយការណ៍ដោយឯករាជ្យភាពតំណាងគ្រឹះស្ថាន ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងការវាយតម្លៃហានិភ័យ ទៅជា ០៣ជំហ៊ានសំខាន់ៗ រួមមាន៖ ការកំណត់អត្តសញ្ញាណ ការវិភាគ និងការវាយតម្លៃ នៃប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យ ដើម្បីរាយការណ៍ទៅកាន់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា "**ស.ហ.ក**" ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

# ៤ លទ្ធផលប្រតិបត្តិការ

## ៤.១ ប្រតិបត្តិការអាជីវកម្ម

នៅដើមឆ្នាំ ២០២០ វិស័យហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់មួយក្នុងការជួយជ្រុមជ្រែងទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ និងធុរកិច្ច ឱ្យមានការរីកចម្រើន ។ ទន្ទឹមនឹងដំណាក់កាលនៃការរីករាលដាលជម្ងឺកូវីត១៩ វិស័យមីក្រូហិរញ្ញវត្ថុ នៅតែបន្តការអភិវឌ្ឍន៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឈមជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ដែលរងផលប៉ះពាល់ដោយវីរ៉ុសកូវីត១៩ តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុសង្គ្រោះបន្ទាន់ ដល់អាជីវកម្មខ្នាតតូច និងមធ្យម សេដ្ឋកិច្ចគ្រួសារ ឬផ្តល់ការរៀបចំឥណទានឡើងវិញ ឲ្យបានល្អប្រសើរបំផុត សម្រាប់សហគមន៍របស់ពួកគេ ។ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានចាប់ផ្តើមបង្កើតឡើងនូវប្រាក់កម្ចីសង្គ្រោះបន្ទាន់ ប្រាក់កម្ចីរយៈពេលខ្លី ផ្តល់ដល់អាជីវកម្មថ្មីៗជាច្រើន ដើម្បីលើកកំពស់ជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋ ស្របទៅតាមយុទ្ធសាស្រ្តចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា និង អភិក្រមដឹកនាំទាំង៥ ***(ឆ្លុះ កញ្ចក់ > ងូតទឹក > ដុសក្អែល > ព្យាបាល > វះកាត់)*** របស់ សម្តេច អគ្គមហាសេនាបតីតេជោ ***ហ៊ុន សែន*** ក្នុងនាមជាបុរសខ្លាំង ដែលបានដឹកនាំប្រទេសកម្ពុជាឱ្យមានសុខសន្តិភាពយូរអង្វែង ***(អរគុណសន្តិភាព)*** ។

ក្នុងកំឡុងឆ្នាំ ២០២០ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានធ្វើវិសោធនកម្មយ៉ាងច្រើន ទៅលើ គោលនយោបាយផ្ទៃក្នុង នីតិវិធី ផលិតផល សេវាកម្ម និងរបៀបរបបនៃការដឹកនាំថ្មី រួមទាំងការបង្កើនផលិតភាពការងារ និងប្រសិទ្ធភាពការងារ ដើម្បីប្រឈមនឹងការរីករាលដាលវីរ៉ុសកូវីត១៩ជាសកល ឆ្ពោះទៅកាន់ឧត្តមភាពនៃការប្រកួតប្រជែង ក្នុងការចាប់យកចំណែកទីផ្សារ នៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ឬសកលភាវូបនីយកម្ម។ ដើម្បីបង្កើនចំណែកទីផ្សាររបស់ **ប៊ីអេអឹមស៊ី** ស្របតាម គោលដៅ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃជាស្នូល របស់ **ប៊ីអេអឹមស៊ី** ដែលបានដាក់ចេញឱ្យអនុវត្ត ទៅគ្រប់បុគ្គលិក និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដោយត្រូវខិតខំប្រឹងប្រែងបំពេញការងារ និងធ្វើការដោយភាពឆ្លាតវៃ ក្នុងការស្វែងរកប្រាក់ចំណេញ ប្រកបដោយ គុណធម៌ក្នុងការគាំពារអតិថិជន ក្រមសីលធម៌វិជ្ជាជីវៈ សមធម៌ការងារ អភិបាលកិច្ចក្រុមហ៊ុន ការត្រួតពិនិត្យផ្ទៃក្នុង និងអនុលោមភាពតាម ច្បាប់ និងបទប្បញ្ញត្តិនានា របស់ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមចុងឆ្នាំ ២០២០ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានអភិរក្សការិយាល័យប្រតិបត្តិការចំនួន **បី** ដដែល រួមមានដូចខាងក្រោម៖

១, **ទីស្នាក់ការកណ្តាល (ចំការដូង)** អាស័យដ្ឋាន៖ ផ្ទះលេខ ៣១៥អា ផ្លូវលេខ ២១៧ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ **ទូរស័ព្ទទំនាក់ទំនងលេខ៖** ០២៣ ៩១១ ០០០

២, **ការិយាល័យសាខា ភ្នំពេញថ្មី** មានអាស័យដ្ឋាន៖ ផ្ទះលេខ ១៥៣សេ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ **ទូរស័ព្ទទំនាក់ទំនងលេខ៖** ០២៣ ៩១១ ០០៥

៣, **ការិយាល័យសាខា ស្រុកកៀនស្វាយ** មានអាស័យដ្ឋាន៖ ផ្ទះលេខ អា-៤៥ ផ្លូវជាតិលេខ ១ ភូមិភូមិធំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ **ទូរស័ព្ទទំនាក់ទំនងលេខ៖** ០២៣ ៩១១ ០០៧

- **ម៉ោងធ្វើការ៖** ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ (៧:០០ ព្រឹក - ៤:០០ ល្ងាច)
- **ម៉ោងបម្រើការ៖** ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ (៧:៣០ ព្រឹក - ៣:៣០ ល្ងាច)
- **បណ្តាញទំនាក់ទំនងរហ័ស ប៊ីអេអឹមស៊ី៖**

- លោក **ខុម រតនៈ** **លេខទំនាក់ទំនង៖** ០៧០ ៥៥៥ ០៨១ **អ៊ីម៉ែល៖** rathanak.khom@bamc.com.kh
- លោក **បូ សុធារ៉ា** **លេខទំនាក់ទំនង៖** ០១៦ ៥៥៥ ៣២៨ **អ៊ីម៉ែល៖** sotheara.bo@bamc.com.kh
- លោក **នឿក សារ៉េត** **លេខទំនាក់ទំនង៖** ០៧០ ៥៥៥ ៧៣៦ **អ៊ីម៉ែល៖** saret.noeuk@bamc.com.kh

គិតជាលទ្ធផលប្រចាំឆ្នាំ ២០២០ គ្រឹះស្ថាន **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានផ្តល់សេវាកម្មប្រាក់កម្ចីជូនដល់អតិថិជនទាំងខាងក្នុង និងខាងក្រៅ បានចំនួនសរុប ៨ រាជធានី/ខេត្ត **៣២** ក្រុង/ស្រុក/ខណ្ឌ **១១៨** ឃុំ/សង្កាត់ និង **១៧៤** ភូមិ ដែលសម្រេចបានជាលទ្ធផល ដូចមានលម្អិតខាងក្រោម៖

១, **អតិថិជនសកម្មសរុប** មានចំនួន **២៩៥ នាក់** ក្នុងឆ្នាំ២០២០ បើប្រៀបធៀបទៅឆ្នាំ២០១៩ មានចំនួន **៣៩៨ នាក់** ដោយថយចុះ អតិថិជនសកម្មសរុបចំនួន **១០៣ នាក់** គិតជាភាគរយ ស្មើរនឹង **(២៥.៨៨ %)**

២, **ផលបត្រឥណទានសរុប** មានចំនួន **១៦,៣៨៧.៣៨ លានរៀល** ក្នុងឆ្នាំ២០២០ បើប្រៀបធៀបទៅឆ្នាំ ២០១៩ ផលបត្រឥណទានសរុប មានចំនួន **១៥,២៩៣.៥៣ លានរៀល** ដោយមានការកើនឡើង ចំនួន **១,០៩៣.៨៥ លានរៀល** គិតជាភាគរយ ស្មើរនឹង **៧.១៥ %**

៣, **ទំហំឥណទានគិតជាមធ្យម** ផ្តល់ទៅអតិថិជនក្នុង **០១ នាក់** មានចំនួនស្មើរនឹង **៥៥.៥៥ លានរៀល** ក្នុងឆ្នាំ ២០២០ បើប្រៀបធៀបទៅឆ្នាំ២០១៩ ទំហំឥណទានគិតជាមធ្យម ផ្តល់ទៅអតិថិជនក្នុង **០១ នាក់** មានចំនួនស្មើរនឹង **៣៨.៤២ លានរៀល**

៤, **ផលបត្រឥណទាន គិតជារូបិយវត្ថុជាតិ (រៀល)** អនុវត្តន៍តាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ឱ្យបាន **១០ %** គ្រឹះស្ថានសម្រេចបាន **១៣.៥៥ %** ក្នុងឆ្នាំ២០២០

៥, **ឥណទានផ្តល់ទៅអតិថិជន** ក្នុងឆ្នាំ២០២០ និង ២០១៩ រួមមានដូចខាងក្រោម៖

**(ក). វិភាគតាមប្រភេទរូបិយប័ណ្ណ**

| | ២០២០ | | | ២០១៩ |
|---|---|---|---|---|
| | **គិតជាភាគរយ** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** |
| ដុល្លារអាមេរិក | ៨៦.៤៥ % | ៣.៥៤១.៨០៨ | ១៤.៣២៦.៦១៣ | ២.៩៩៩.០១៩ |
| ខ្មែររៀល | ១៣.៥៥ % | ៥៥៥.២០២ | ២.២៤៥.៧៩២ | ៧៥៣.៩៩៥ |
| | ១០០ % | ៤.០៩៧.០១០ | ១៦.៥៧២.៤០៥ | ៣.៧៥៣.០១៤ |

(ខ). វិភាគតាមកត្តាសេដ្ឋកិច្ច

| | ២០២០ | | | ២០១៩ |
|---|---|---|---|---|
| | គិតជាភាគរយ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| កសិកម្ម | ៦.១៤ % | ២៥១.៤៣៥ | ១.០១៧.០៥៤ | ៣៩៣.០៩៣ |
| សំណង់ | ១៧.០៥ % | ៦៩៨.៤៧៥ | ២.៨២៥.៣៣១ | ៥៩០.១២០ |
| គ្រួសារ | ១៣.៣៦ % | ៥៤៧.៦៦៣ | ២.២១៥.២៩៧ | ៦០៩.៨៨៧ |
| សេវាកម្ម | ៣០.៦៥ % | ១.២៥៥.៨១៧ | ៥.០៧៩.៧៨០ | ១.១៤៧.៧៧៤ |
| ជំនួញ និងពាណិជ្ជកម្ម | ១១.៨៨ % | ៤៨៦.៩២៥ | ១.៩៦៩.៦១២ | ៦៤៩.៣៨៥ |
| មធ្យោបាយដឹកជញ្ជូន | ១.៥៩ % | ៦៤.៨៤៧ | ២៦២.៣០៦ | ១៩៩.០៧៤ |
| ផ្សេងៗទៀត | ១៩.៣៣ % | ៧៩១.៨៤៨ | ៣.២០៣.០២៥ | ២០៣.៦៨១ |
| | ១០០ % | ៤.០៩៧.០១០ | ១៦.៥៧២.៤០៥ | ៣.៧៥៣.០១៤ |

(គ). វិភាគតាមសម្ព័ន្ធភាគី

| | ២០២០ | | | ២០១៩ |
|---|---|---|---|---|
| | គិតជាភាគរយ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជនខាងក្រៅ | ៩៥.៥១ % | ៣.៩១៣.០៩៤ | ១៥.៨២៨.៤៦៥ | ៣.៧០៦.៨២៧ |
| ឥណទានទៅបុគ្គលិក | ៤.៤៩ % | ១៨៣.៩១៦ | ៧៤៣.៩៤០ | ៤៦.១៨៧ |
| | ១០០ % | ៤.០៩៧.០១០ | ១៦.៥៧២.៤០៥ | ៣.៧៥៣.០១៤ |

## ៤.២ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

**សេវាកម្មហិរញ្ញវត្ថុ៖** ១. ឥណទានអាជីវកម្ម    ២. ឥណទានរយៈពេលខ្លី

៣. ឥណទានគេហដ្ឋាន    ៤. ឥណទានរថយន្ត

**ផលិតផលហិរញ្ញវត្ថុ៖** ១. រូបិយវត្ថុជាតិ (រៀល)    ២. រូបិយបណ្ណអន្តរជាតិ (ដុល្លារអាមេរិក)

## ៤.៣ អភិបាលកិច្ចធនធានមនុស្ស

### ៤.៣.១ ព័ត៌មានបុគ្គលិកនិយោជិត

គិតមកត្រឹមចុងឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** មានបុគ្គលិកនិយោជិតបម្រើការងារ រាប់បញ្ចូលទាំង បុគ្គលិកបរទេស ០២រូប ជាជនជាតិកូរ៉េខាងត្បូង ដូចមានលម្អិត ក្នុងតារាងខាងក្រោម៖

| ល.រ | មុខតំណែង / នាយកដ្ឋាន / ការិយាល័យសាខា | ចំនួននិយោជិត | ភេទប្រុស | ភេទស្រី |
|---|---|---|---|---|
| 1 | អគ្គនាយកប្រតិបត្តិ | ០១ | ០១ | |
| 2 | នាយកប្រតិបត្តិ | ០១ | ០១ | |
| 3 | នាយកដ្ឋានប្រតិបត្តិតាម និងហានិភ័យ | ០២ | ០២ | |
| 4 | នាយកដ្ឋានព័ត៌មានវិទ្យា | ០២ | ០២ | |
| 5 | នាយកដ្ឋានហិរញ្ញវត្ថុ | ០៣ | ០២ | ០១ |
| 6 | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ០២ | ០២ | |
| 7 | នាយកដ្ឋានប្រតិបត្តិការ | ០៣ | ០៣ | |
| 8 | នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល | ០១ | ០១ | |
| 9 | សាខាភ្នំពេញថ្មី | ០៦ | ០៣ | ០៣ |
| 10 | សាខាកៀនស្វាយ | ០៤ | ០២ | ០២ |
| 11 | សាខាការិយាល័យកណ្ដាល (ចំការដូង) | ០៣ | ០១ | ០២ |
| | **សរុបចំនួននិយោជិក** | **២៨** | **២០** | **០៨** |

### ៤.៣.២ អត្ថប្រយោជន៍បុគ្គលិកនិយោជិត

(ក) **អត្ថប្រយោជន៍និយោជិករយៈពេលខ្លី**

ប្រាក់ឈ្នួល ប្រាក់បៀវត្ស វិភាគទានសន្តិសុខសង្គម ប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំ ប្រាក់បង់ការឈប់សម្រាកពេលឈឺ អត្ថប្រយោជន៍បន្ថែម និងអត្ថប្រយោជន៍មិនមែនសាច់ប្រាក់ គឺត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានមិនគិតអប្បហារ និងត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលនិយោជិតទាំងនោះបានបំពេញការងារឱ្យក្រុមហ៊ុន។

ប្រាក់សំណងបង្គររយៈពេលខ្លី រួមមានប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំ ដែលត្រូវបានកំណត់ ដោយបានទទួលស្គាល់ជាចំណាយនៅពេលនិយោជិតទាំងនោះ បានបម្រើការងារដោយបង្កើនសិទ្ធិទទួលបានរបស់ ពួកគាត់នៅថ្ងៃអនាគត ។ អវត្តមានរយៈពេលខ្លីមិនបង្គរសម្រាប់ទូទាត់ ដូចជាការឈប់សម្រាកឈឺ ត្រូវបាន ទទួលស្គាល់នៅពេលដែលអវត្តមាននោះកើតឡើង ហើយប្រសិនបើការឈប់សម្រាកនោះមិនត្រូវបាន ប្រើប្រាស់ទាំងស្រុងនៅក្នុងការិយបរិច្ឆេទទេ និយោជិតនឹងមិនត្រូវបានទូទាត់ជូនជាសាច់ប្រាក់នៅចុងការិយបរិច្ឆេទ ឬ នៅពេលដែលលាឈប់ពីក្រុមហ៊ុនឡើយ។ អត្ថប្រយោជន៍បន្ថែម គឺត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមានកាតព្វកិច្ចផ្លូវ

ច្បាប់ ឬកាតព្វកិច្ច ដែលបង្កើតឡើងនាពេលបច្ចុប្បន្នតម្រូវឱ្យមានការបង់ប្រាក់ ដែលជាលទ្ធផលកើតចេញពីព្រឹត្តិការណ៍កន្លងមក និងនៅពេលដែលមានការប៉ាន់ស្មានជាក់លាក់ អាចត្រូវបានធ្វើឡើងពីចំនួននៃកាតព្វកិច្ច ។

(ខ) **អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ**

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារ មុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត ។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្ត ដោយនិយោជិតលើសពីតម្រូវការអត្ថប្រយោជន៍នោះ ត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលការស្នើសុំនេះ ។ នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារហួសការជំពាក់កំណត់លើសពី ១២ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្នដោយផ្អែកលើលទ្ធផលទីផ្សារនៅចុងការិយបរិច្ឆេទ ។

## ៤.៣.៣ ការអភិវឌ្ឍបុគ្គលិកនិយោជិត

នៅឆ្នាំ២០២០នេះ **ប៊ីអេអឹមស៊ី** មានផែនការជាក់លាក់ ក្នុងការបណ្តុះបណ្តាលដល់និយោជិកដែលមានស្រាប់ និងថ្មី ដែលត្រូវបានធ្វើការតម្រង់ទិស ដើម្បីធ្វើឱ្យប្រសើរឡើងនូវ ជំនាញ សមត្ថភាព ចំណេះដឹង និងការអនុវត្តការងារ យោងទៅតាមការពិពណ៌នាការងាររៀងៗខ្លួន ដោយត្រូវអនុវត្តឱ្យស្របទៅតាម យុទ្ធសាស្ត្រ ឆ្នាំ២០២០ គោលដៅ ចក្ខុវិស័យ បេសកកម្ម គុណតម្លៃស្នូល និងបាវចនាខាងក្នុង **ប៊ីអេអឹមស៊ី ! សម្រាប់ក្រុមគ្រួសារ, ប៊ីអេអឹមស៊ី! ល្អជាច់គេ ។**

**ប៊ីអេអឹមស៊ី** បានបើកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកនិយោជិកជាទៀងទាត់ នៅរៀងរាល់ ពេលព្រឹកថ្ងៃសៅរ៍ ចាប់ពីម៉ោង ០៨ នាទីព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់ ដល់បុគ្គលិកនិយោជិកទាំងអស់ មកពីគ្រប់ការិយាល័យសាខា នៅសាលប្រជុំខាងលើ នៃការិយាល័យកណ្តាលរបស់គ្រឹះស្ថាន ដោយមានគ្រូបង្គោលជាតំណាង ដែលត្រូវបានតែងតាំងចេញពីនាយកដ្ឋានជំនាញនីមួយៗ ក្នុងការហ្វឹកហ្វឺន និងបង្ហាត់បង្រៀន ដល់បុគ្គលិកនិយោជិក។

គោលបំណងសំខាន់នៃការបណ្តុះបណ្តាលនេះ គឺដើម្បីពង្រឹងដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ឱ្យមានសមត្ថភាព និងជំនាញពេញលេញក្នុងការងារប្រកបដោយ ស្មារតីទទួលខុសត្រូវខ្ពស់ មានទំនុកចិត្តលើខ្លួនឯង និងសាមគ្គីភាព តាមរយៈការចែករំលែកមតិយោបល់ទាំងវិជ្ជមាន និងអវិជ្ជមាន ក្នុងន័យស្ថាបនា ជាមួយមិត្តរួមការងារ និងគណៈគ្រប់គ្រងរបស់គ្រឹះស្ថាន ក្នុងការពួតដៃគ្នាកសាង **ប៊ីអេអឹមស៊ី** ឱ្យកាន់តែមានភាពរីកចម្រើនដូចពេលបច្ចុប្បន្ន និងទៅអនាគត ដើម្បីក្លាយខ្លួនទៅជា **ធនាគាររិកដ៏ល្អឆ្នើមបំផុត** នាយុគសម័យបច្ចេកវិទ្យាដ៏ទំនើបនេះ។

## ៤.៣.៤ កម្រិតចំណាត់ថ្នាក់មុខតំណែង និងការលើកទឹកចិត្ត

ចាប់តាំងពីដើមឆ្នាំ២០២០មក **ប៊ីអេអឹមស៊ី** បានធ្វើកំណែទម្រង់យ៉ាងច្រើន លើកម្រិតចំណាត់ថ្នាក់ និងមុខតំណែងនីមួយៗជា **១១ កម្រិត** ដោយរាប់ចាប់ពីមន្ត្រីថ្នាក់ទាប រហូតទៅដល់ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដែលមានភ្ជាប់មកជាមួយនូវ ការលើកទឹកចិត្តទាំងបែបហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ រួមមានដូចជា៖ ការតំឡើងឋានៈតួនាទី ការតែងតាំងតួនាទីស្តីទី ការផ្តល់ជារង្វាន់ ការផ្តល់ជាលិខិត ឬបណ្ណសរសើរ ដល់បុគ្គលិកនិយោជិកដែលសម្រេចបានលទ្ធផលការងារល្អប្រសើរនិងអត្ថប្រយោជន៍បន្ថែមផ្សេងៗ ដែលផ្តល់ជូនដោយអគ្គនាយកប្រតិបត្តិរបស់គ្រឹះស្ថានទៅកាន់បុគ្គលិកនិយោជិកគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រណាំងប្រជែងបំពេញការងារ និងសម្រេចបានលទ្ធផលល្អជាច់គេ លើសផែនការគ្រោងទុក នៅក្នុងយុទ្ធនាការប្រតិបត្តិការអាជីវកម្ម របស់គ្រឹះស្ថាន ដែលបានដាក់ចេញឱ្យអនុវត្ត ។

ទន្ទឹមនឹងនេះដែរ សម្រាប់ការលើកទឹកចិត្តបែបហិរញ្ញវត្ថុជាច្រើន ក៏ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ជូនបុគ្គលិកនិយោជិកគ្រប់ជាន់ថ្នាក់ ដែលសុទ្ធតែមានចែងនៅក្នុងគោលនយោបាយ និងនីតិវិធី ថ្មីៗរបស់គ្រឹះស្ថាន ដែលទទួលបានការអនុម័ត ពីក្រុមប្រឹក្សាភិបាល ដោយមានជំនួយពីគណៈកម្មការធនធានមនុស្ស ជាអ្នកទទួលបន្ទុក អនុវត្តឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។ ជាការពិតណាស់ ឆ្នាំនេះ **ប៊ីអេអឹមស៊ី** បានផ្អាករៀបចំឱ្យមានសិក្ខាសាលាប្រចាំឆ្នាំតាមរយៈដំណើរកំសាន្ត ជូនដល់បុគ្គលិកនិយោជិក និងថ្នាក់គ្រប់គ្រងទាំងអស់ ដោយចូររួមជាមួយរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីត១៩ ក្នុងប្រទេសកម្ពុជា ។

កាលពីឆ្នាំមុន២០២០ នាខែកុម្ភៈ **ប៊ីអេអឹមស៊ី** បានរៀបចំឱ្យមានសិក្ខាសាលាប្រចាំឆ្នាំតាមរយៈដំណើរកំសាន្តទៅកាន់ខេត្តកំពត ដែលមានរយៈពេល០២ថ្ងៃ និង០១យប់ នៅរមណីយដ្ឋានដ៏សែនស្រស់ស្អាតជាច្រើនកន្លែង ដែលមានការរៀបចំកម្មវិធីកម្សាន្តសប្បាយដូចជា៖ វគ្គសិក្ខាសាលារយៈពេលខ្លី ការទទួលទានអាហារសាមគ្គីរួមគ្នា ការច្រៀងរាំលេងកម្សាន្ត ការលេងល្បែងប្រជាប្រិយ ការល្បងប្រាជ្ញា ការចាប់រង្វាន់ផ្សងសំណាង និងកម្មវិធីសប្បាយផ្សេងៗ ជាច្រើនទៀត ដែលបានបង្កើតបរិយាកាសដ៏សែនរីករាយ និងអនុស្សាវរីយ៍ល្អៗ ធ្វើឱ្យបុគ្គលិក និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បាត់អស់នៅក្តីទុកកង្វល់ រសាយបាត់ទៅតាមបរិយាកាស និងបានផ្តល់ឱកាស ដល់បុគ្គលិក និងថ្នាក់ដឹកនាំ កាន់តែមានភាពស្និទស្នាលនឹងគ្នា ទៅវិញទៅមក ក្នុងនាមជាគ្រួសារការងារដ៏រឹងមាំតែមួយ និងឈរជាថ្លងមួយ ពួតដៃគ្នាកសាង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ឱ្យកាន់តែមានភាពរីកចម្រើន និងទទួលបានប្រាក់ចំណេញយូរអង្វែង ដែលធ្វើឱ្យប្រតិបត្តិការអាជីវកម្មមាននិរន្តរភាព ឈរក្រោមឈ្មោះ **ប៊ីអេអឹមស៊ី** គឺជាក្រុមគ្រួសារតែមួយ។

### ៤.៣.៥ អភិក្រមដឹកនាំឆ្នាំ២០២០ និងសិក្ខាបទការងារ ទាំង ១០-ស

- អនុសាសន៍ ៖ ការផ្លាស់ប្តូរ > ការប្រឈម > កិច្ចសហប្រតិបត្តិការ > ការទំនាក់ទំនង
- ឥណទាន ៖ អត្តចារិក > លទ្ធភាពសង > មូលធនទ្រព្យសម្បត្តិ > ទ្រព្យតម្កល់ធានា > លក្ខខណ្ឌព្រមព្រៀង
- ៣ ការពារ ៖ អភិបាលកិច្ចក្រុមហ៊ុន > អនុលោមភាពបទប្បញ្ញត្តិ > សុភវិនិច្ឆ័យ
- ៣ កុំ ៖ យកសោហ៊ុយក្រៅផ្លូវការ > ចូលរួមអំពើពុករលួយ > ជាប់ពាក់ព័ន្ធបទឧក្រិដ្ឋ
- សិក្ខាបទការងារទាំង (១០-ស) ៖

សម្រិត > សម្រួល > សម្អាត > សន្សំសំចៃ > សម្ដី > សម្ងាត់ > សុវត្ថិភាព > សន្តិសុខ > ស្ថិរភាព > ស៊ើប

### ៤.៣.៦ បទបញ្ជាផ្ទៃក្នុង និងវិធានទោសវិន័យធនធានមនុស្ស

- **បទបញ្ជាផ្ទៃក្នុង ប៊ីអេអឹមស៊ី** ត្រូវបានតាក់តែងឡើងជាគោលការណ៍ប្រតិបត្តិ និងអនុម័តដោយក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំ អនុលោមតាមសារាចរណ៍ ឬសេចក្តីណែនាំនានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ គោលការណ៍ផ្ទៃក្នុងនេះ ក៏បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ដោយសាលារាជធានីភ្នំពេញ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។

- **គោលការណ៍វិធានទោសវិន័យធនធានមនុស្ស** ត្រូវបានធ្វើវិសោធនកម្មដោយគណៈកម្មការធនធានមនុស្ស ក្នុងឆ្នាំ២០២០ ដើម្បីកំណត់ចេញជាក្រមប្រតិបត្តិសីលធម៌វិជ្ជាជីវៈ និងជានីតិវិធីពិន័យដល់ អ្នកណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងកំហុសធ្ងន់ ។ គោលការណ៍ផ្ទៃក្នុងនេះ ទាមទារតម្រង់ឆ្ពោះទៅសមធម៌ ក្នុងលក្ខខណ្ឌព្រមព្រៀង នៃកិច្ចសន្យាការងារ ការរំលាយកិច្ចសន្យាការងារ និងការបណ្តេញចេញពីការងារ ។

## ៤.៤ សវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង

គណៈកម្មការសវនកម្ម ដែលមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាសេនាធិការ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង ទាំងលើដំណើរការ និងប្រតិបត្តិការអាជីវកម្ម របស់គ្រឹះស្ថាន គ្រប់ការិយាល័យសាខាទាំងអស់ ដែលបានប្រគល់សិទ្ធពេញលេញពីគ្រឹះស្ថាន និងធនាគារជាតិនៃកម្ពុជា ដែលបានអនុម័តទទួលស្គាល់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ដល់មន្ត្រីសវនករផ្ទៃក្នុងជាន់ខ្ពស់ ក្នុងការអនុវត្តការងារ ឬការបំពេញតួនាទីរបស់ខ្លួន ប្រកបដោយឯករាជ្យភាព និងការស្វែងរកបកគំហើញ ដែលមិនបានអនុលោម តាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។

គិតមកត្រឹមចុងឆ្នាំ២០២០ នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានបុគ្គលិកបម្រើការងារសរុបចំនួន ០២រូប និងគណៈកម្មការសវនកម្មមានសមាជិកចំនួន ០៣រូប ដោយប្រធានគណៈកម្មការសវនកម្ម ជាសមាជិក ០១រូប នៅក្នុងក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ។ ទន្ទឹមនឹងនេះដែរ នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺមានផែនការប្រចាំឆ្នាំយ៉ាងច្បាស់លាស់មួយដោយបានរៀបចំឡើង នៅរៀងរាល់បំណាច់ឆ្នាំនីមួយៗ ដើម្បីដាក់ជូនគណៈកម្មការសវនកម្មរបស់ខ្លួន ធ្វើការត្រួតពិនិត្យ និងអនុម័ត នឹងដាក់ឱ្យអនុវត្តជាផ្លូវការ ដើម្បីប្រសិទ្ធិភាពការងារ នៅឆ្នាំបន្តបន្ទាប់ទៀត ។

ការរៀបចំកម្មវិធីសវនកម្ម របស់នាយកដ្ឋាន គឺត្រូវធ្វើឡើងដោយស្របទៅនឹង គោលការណ៍នៃច្បាប់ និងបទប្បញ្ញត្តិផ្សេងៗរបស់គ្រឹះស្ថាន ព្រមទាំងអនុលោមទៅនឹង គោលការណ៍ច្បាប់ ប្រកាស និងបទបញ្ញាតិផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជាផងដែរ ។ មន្ត្រីសវនករត្រូវបានចាត់តាំងឱ្យធ្វើសវនកម្ម គ្រប់ការិយាល័យសាខាទាំងអស់ ជារៀងរាល់ខែ ទៅលើកិច្ចការ ឥណទាន ហិរញ្ញវត្ថុ រដ្ឋបាល និងផ្នែកដែលពាក់ព័ន្ធផ្សេងៗទៀត ដោយស្របទៅនឹងកម្មវិធីសវនកម្មប្រចាំខែនីមួយៗ ។ រាល់ចំណុចខ្វះខាតដែលបានរកឃើញ គឺមានភស្តុតាងបញ្ជាក់យ៉ាង ច្បាស់លាស់ ត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលត្រូវបានលើកឡើងយកមកជជែកពិភាក្សានៅក្នុងនាយកដ្ឋានសាមី ដើម្បីធ្វើការកែប្រែ និងផ្តល់ជាអនុសាសន៍ល្អៗ ក្នុងការកែលម្អ នៅក្នុងកម្រិតដែលអាចទទួលយកបាន។ រាល់កង្វះខាតដែលបានរកឃើញ ត្រូវបានតាមដាន និងត្រួតពិនិត្យ យ៉ាងយកចិត្តទុកដាក់បំផុត ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង គណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាល។

ការទទួលខុសត្រូវរបស់នាយកដ្ឋានផ្សេងៗ ដែលបានរកឃើញថាមានកំហុស ក្នុងការអនុវត្តការងាររបស់ខ្លួន គឺត្រូវតែបញ្ចេញមតិយោបល់ទទួលស្គាល់ ឬកែប្រែកំហុស និងផ្តល់ជាអនុសាសន៍ ចេញជាផែនការសកម្មភាពទៅលើ របាយការណ៍ទាំងអស់ ដែលបានរកឃើញដោយមន្ត្រីសវនករជាន់ខ្ពស់ ទៅលើការធ្វើសវនកម្មជាក់ស្តែង បន្ទាប់មកត្រូវចម្លងជូនរបាយការណ៍នោះបន្ត ទៅកាន់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការត្រួតពិនិត្យ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវមានសមាសភាពតំណាង ក្នុងការចូលរួមប្រជុំជាប្រចាំសប្តាហ៍ នៅរៀងរាល់ថ្ងៃសុក្រ និងត្រូវធ្វើបទបង្ហាញពីរបាយការណ៍សវនកម្មរបស់ខ្លួននៅរៀងរាល់កិច្ចប្រជុំប្រចាំខែ របស់គណៈគ្រប់គ្រង។ នៅរាល់ពេលដែលមានការរកឃើញ របកគំហើញលើករណីសវនកម្មពិសេស មន្ត្រីសវនករត្រូវរាយការណ៍ភ្លាមៗទៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង គណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការសម្រេចចិត្តឱ្យទាន់ពេល។

## ៤.៥ ហានិភ័យ និងអនុលោមភាព

គណៈកម្មការប្រតិបត្តិតាម និងហានិភ័យ ដែលមាននាយកដ្ឋានប្រតិបត្តិតាម និងហានិភ័យ ជាសេនាធិការនឹងមានអភិបាលឯករាជ្យ នៃសមាជិកក្រុមប្រឹក្សាភិបាល ជាប្រធានគណៈកម្មការប្រតិបត្តិតាម និងហានិភ័យ ដោយមានប្រធានមុខងារប្រតិបត្តិតាម និងមន្ត្រីប្រតិបត្តិជាន់ខ្ពស់ ដែលត្រូវបានអនុម័តទទួលស្គាល់ដោយ ធនាគារជាតិនៃកម្ពុជា និងអង្គភាពសើុបការហិរញ្ញវត្ថុកម្ពុជា ដែលហៅកាត់ថា "**ស.ហ.ក**" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ និងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ក្នុងការអនុវត្តការងារ ឬការបំពេញតួនាទីរបស់ខ្លួន ប្រកបដោយឯករាជ្យភាព លើការរាយការណ៍ នូវរបាយការណ៍ជាមូលដ្ឋានគ្រឹះ ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំពីរសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ប្រចាំពីរឆ្នាំ និងប្រចាំបីឆ្នាំ ។ រាល់របាយការណ៍ទាំងអស់នឹងត្រូវផ្ញើទៅតាមពេលវេលាផ្សេងៗគ្នាទៅកាន់ ធនាគារជាតិនៃកម្ពុជា អង្គភាពសើុបការហិរញ្ញវត្ថុកម្ពុជា សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទានក្រេឌីតប្យូរ៉ូ (CBC) ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងរួមទាំង ក្រសួង ស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា ។

## ៤.៦ គោលនយោបាយ និងនីតិវិធី វិស្សលប្លូវីង

គោលនយោបាយ និងនីតិវិធី វិស្សលប្លូវីង គឺជាការពិពណ៌នាអំពី ក្រមប្រតិបត្តិសីលធម៌វិជ្ជាជីវៈ ដែលបានរៀបចំឡើងដោយ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ អតិថិជន និយោជិក និយោជក អ្នកវិនិយោគគិន ម្ចាស់ភាគហ៊ុន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត ដែលរងផលប៉ះពាល់នៅក្នុងដំណើរការ និងប្រតិបត្តិការអាជីវកម្មរបស់ **ប៊ីអេអឹមស៊ី** ។

គោលនយោបាយ និងនីតិវិធី វិស្សលប្លូវីង គឺត្រូវបានរៀបចំបង្កើតឡើងដោយ នាយកដ្ឋានប្រតិបត្តិតាម និងហានិភ័យ នៃ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ដែលបានអនុម័ត ដោយអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភាគទុនិកចុះនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និង មានគោលបំណងសំខាន់ៗដូចមានរៀបរាប់ជាសង្ខេប ខាងក្រោម ៖

- ធានាថានិយោជិកទាំងអស់ទទួលបានការគាំទ្រក្នុងសេចក្តីថ្លែងការណ៍ដោយមានទំនុកចិត្ត និងរាយការណ៍អំពីបញ្ហាដែលពួកគេសង្ស័យថាអាចពាក់ព័ន្ធនឹងអ្វីដែលមិនសមរម្យគ្មានក្រមសីលធម៌ និងគ្មានវិជ្ជាជីវៈ ។
- លើកទឹកចិត្តដល់អ្នកប្តឹងតវ៉ាឱ្យកំណត់ និងប្រឆាំងរាល់ឥរិយាបទមិនសមរម្យដែលគ្មានក្រមសីលធម៌វិជ្ជាជីវៈ ដូចជាការប្រើប្រាស់ទ្រព្យសម្បត្តិមិនត្រឹមត្រូវ ឬទទួលបានអត្ថប្រយោជន៍ពីប្រតិបត្តិការអាជីវកម្មរបស់ **ប៊ីអេអឹមស៊ី** នៅគ្រប់កម្រិតទាំងអស់ ។
- ផ្តល់ក្របខណ្ឌច្បាស់លាស់សម្រាប់ការរាយការណ៍ និងការដោះស្រាយក្តីកង្វល់ទាំងអស់នេះ ។
- គ្រប់គ្រងរាល់ការលាតត្រដាង ឬបណ្តឹងតវ៉ាឱ្យបានសមស្រប ទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈខ្ពស់ ។
- ផ្តល់ការធានាដល់ការលាតត្រដាង ឬបណ្តឹងតវ៉ាទាំងអស់ត្រូវបានយកចិត្តទុកដាក់ជាការសម្ងាត់ និងគ្រប់គ្រងដោយគ្មានការភ័យខ្លាចពីការសងសឹកគ្រប់ទម្រង់រូបភាពណាមួយឡើយ ។
- ដើម្បីជួយលើកកម្ពស់ និងអភិវឌ្ឍវប្បធម៌ដោយការបើកចំហ គណនេយ្យភាព និងសុចរិតភាពរបស់ **ប៊ីអេអឹមស៊ី** ។

បណ្តាញ និងព័ត៌មានសំខាន់ៗ នៃវិស្សលប្លូវីង ដែលអ្នកប្តឹងតវ៉ាអាចលើកឡើងពីការព្រួយបារម្ភរបស់ពួកគេបានតាមរយៈការនិយាយដោយផ្ទាល់មាត់ ការសរសេរជាលាយលក្ខណ៍អក្សរ និងភាពអនាមិក នៅក្នុងទំរង់ផ្លូវការដែលមានទាំងលើក្រដាស និងប្រព័ន្ធអេឡិកត្រូនិក ដែលបានដាក់ចេញឱ្យអនុវត្ត ក្នុងការប្តឹងតវ៉ាប្រកបដោយទំនុកចិត្ត និងការរក្សាបានការសម្ងាត់ខ្ពស់ ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះការប្តឹងតវ៉ា ដែលសរសេរជាលាយលក្ខណ៍អក្សរក្នុងទំរង់ផ្លូវការ **ប៊ីអេអឹមស៊ី វិស្សលប្លូវីង** គឺត្រូវបានលើកទឹកចិត្តក្នុងការប្តឹងតវ៉ា ជាជាងការប្តឹង ឬការលើកឡើងដោយការនិយាយដោយផ្ទាល់មាត់ផងដែរ ដើម្បីបញ្ជូនទៅកាន់នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម ដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព តាមរយៈការសរសេរជាលាយលក្ខណ៍អក្សរ នៅក្នុងទំរង់ជាផ្លូវការ **ប៊ីអេអឹមស៊ី វិស្សលប្លូវីង** ដាក់ចូលក្នុងប្រអប់សម្ងាត់ និងតាមរយៈគេហទំព័រ ឬតាមសារអេឡិកត្រូនិក **អ៊ីម៉ែល** របស់ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ដើម្បីធ្វើការត្រួតពិនិត្យ និងទទួលយក ដែលរួមមានដូចខាងក្រោម ៖

| មុខងារទទួលបន្ទុកផ្ទាល់ | លេខទំនាក់ទំនង |
|---|---|
| **នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម** | **០៧០ ៥៥៥ ០៨១/០៧០ ៦២៤ ៥៥៥ / rc.dept@bamc.com.kh** |

## ៤.៧ ក្របខ័ណ្ឌការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** បានរៀបចំចងក្រងនូវ គោលនយោបាយ និងនីតិវិធី ស្តីពី ការអនុវត្តកាតព្វកិច្ច នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជាជាធរមាន។

គោលនយោបាយ និងនីតិវិធី ស្តីពី ការអនុវត្តកាតព្វកិច្ច នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានធ្វើវិសោធនកម្ម និងអនុម័តសម្រេច ឱ្យប្រើប្រាស់ជាផ្លូវការ ដោយក្រុមប្រឹក្សាភិបាល និងភាគទុនិក នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។ លើសពីនេះទៀត គ្រឹះស្ថានក៏បានដាក់ចេញនូវគោលការណ៍ណែនាំបន្ថែម ស្តីពី វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន (CDD) ការស្គាល់ អតិថិជន (KYC) ការប្រឆាំងការសម្អាតប្រាក់ (AML) និងហិរញ្ញប្បទានភេរវកម្ម (CFT) ដែលត្រូវបានអនុម័តសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយអគ្គនាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដើម្បីអាចជួយបំពេញបន្ថែមលើគោលនយោបាយ និងនីតិវិធី ស្តីពី ការអនុវត្តកាតព្វកិច្ច នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យកាន់តែទទួលបានប្រសិទ្ធិភាព និងប្រសិទ្ធិផលខ្ពស់ ក្នុងរង្វង់គ្រឹះស្ថាន **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** ស្របតាមច្បាប់ ដែលបានធ្វើបច្ចុប្បន្នកម្មថ្មីរបស់ជាតិ។

# ៥ សម្រង់របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្មឆ្នាំ២០២០

## ៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់នូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** តទៅនេះហៅកាត់ថា ("**ក្រុមហ៊ុន ឬគ្រឹះស្ថាន**") សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

**សកម្មភាពចម្បង**

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺជាអ្នកដែលផ្តល់នូវសេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលប្រកបដោយស្ថិរភាពចំពោះសហគ្រាសធុនតូចនិងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងប្រទេសកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

**លទ្ធផលនៃប្រតិបត្តិការ**

| | ដុល្លារអាមេរិក | គិតជាពាន់រៀល |
|---|---|---|
| **ចំណេញសម្រាប់ការិយបរិច្ឆេទ** | **៣៤.៩៧២** | **១៤១.៤៦១** |

## ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការបែងចែកភាគលាភសម្រាប់កំឡុងការិយបរិច្ឆេទនេះទេ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងកំឡុងការិយបរិច្ឆេទនេះទេ ។

## ឥណទានអាក្រក់ និង ឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនចំពោះឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយជឿជាក់ថាឥណទានអាក្រក់ ត្រូវបានជម្រះចេញពីបញ្ជី និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ឥណទានសង្ស័យ ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាល ឱ្យការជម្រះចេញពីបញ្ជីនៃឥណទានអាក្រក់ ឬក៏សំវិធានធនចំពោះឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ត្រូវបានធ្វើឡើងជាសារវន្តឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងឡាយណា ដែលទំនងជាមិនអាចបង្វិលមកវិញបានក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកថានឹងអាចលក់បាននៅលើទីផ្សារ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវឡើយ។

## វិធីសាស្ត្រកំណត់តម្លៃ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង បណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំនេះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសងក្នុង រយៈពេល១២ខែ បន្ទាប់ពីថ្ងៃដំណាច់ឆ្នាំ ដែលនឹង ឬអាចមានការប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យមានចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមហ៊ុនមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាលលទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះមិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយឡើយ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរហូតមកទល់នឹងថ្ងៃចេញរបាយការណ៍នេះ មិនមានខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្ត ដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ ។

## ដើមទុន

ក្រុមហ៊ុនមិនបានបោះផ្សាយភាគហ៊ុនថ្មីកំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុទេ ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុននៃក្រុមហ៊ុននាចុងកំឡុងការិយបរិច្ឆេទនេះទេ ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីរបាយការណ៍ចុងក្រោយ គឺមានរាយនាមបញ្ជាក់ដូចខាងក្រោម៖

លោក ហ៊ុន ពេជ្រ

លោក Kang Dong Hyun

លោក ថុង សុជាត

លោក Park Byung Kwon

លោក Kim Chul Woong

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងកំឡុងពេល និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រុមហ៊ុនមិនបានចូលរួមជាភាគីក្នុងការរៀបចំណាមួយក្នុង គោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាននូវផលប្រយោជន៍ផ្សេងៗតាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាមីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រុមហ៊ុន ឬរវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏រវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវ ទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលត្រូវ៖

ក. ជ្រើសរើសគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យបានជាប់លាប់។

ខ. អនុលោមទៅតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា (“ស.រ.ហ.អ.ក.ស.ធ.ត.ម”) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវ ទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលត្រូវ៖

គ. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្មលើកលែងតែក្នុងករណីសន្មតយ៉ាងសមរម្យថាក្រុមហ៊ុននឹងមិនអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដ៏ខ្លី និង

ង. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ និងស្ថានភាពរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាការសម្រេចចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលអះអាងថាក្រុមហ៊ុនបានអនុវត្តតាមនូវរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

## ព្រឹត្តិការណ៍សំខាន់ៗក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃរបាយការណ៍

ព្រឹត្តិការណ៍សំខាន់ៗក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃរបាយការណ៍ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី៩ ដល់ ៤៥ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## តាងនាមឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក
BAMC FINANCE PLC.
KINGDOM OF CAMBODIA

**លោក Kang Dong Hyun**
អគ្គនាយកប្រតិបត្តិ

**លោក ថុង សុជាត**
អភិបាល

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

# ៥.២ របាយការណ៍របស់សវនករឯករាជ្យ

## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគទុនិកនៃ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជី៖ Co.២០៥៥ KH/២០១៤)

## សេចក្ដីរាយការណ៍លើសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") រួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងសេចក្ដីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត ដែលមានបង្ហាញចាប់ពីទំព័រទី៩ ដល់ ៤៥ ។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក") ។ ទំនួលខុសត្រូវរបស់យើងខ្ញុំបានធ្វើតាមស្តង់ដានេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

### ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយគោរពទៅតាម *ក្រមសីលធម៌របស់គណនេយ្យករជំនាញ និងសវនករ* នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ("ក្រមសីលធម៌") និង*ក្រមសីលធម៌អន្តរជាតិរបស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារអន្តរជាតិនៃឯករាជ្យភាព)* របស់ក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសំរាប់គណនេយ្យករជំនាញ ("ក្រមសីលធម៌ IESBA") ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌ដទៃទៀត ដោយអនុលោមតាមក្រមសីលធម៌របស់គណនេយ្យករជំនាញនេះផងដែរ ។

### ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវនូវព័ត៌មានផ្សេងទៀត ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឯករាជ្យយើងខ្ញុំទេ ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលព័ត៌មានផ្សេងៗហើយយើងមិនបានបង្ហាញពីទម្រង់នៃការសន្និដ្ឋានលើការធានាណាមួយឡើយ ។

ទាក់ទងជាមួយនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនស្របជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ការយល់ដឹងរបស់យើងខ្ញុំទទួលបានពីការធ្វើសវនកម្ម ឬបើមិនដូច្នោះទេកំហុសឆ្គងជាសារវន្តត្រូវបានបង្ហាញ ។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាព័ត៌មានផ្សេងៗមានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍ពីការពិត តែយើងខ្ញុំមិនមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសក្នុងការការត្រួតពិនិត្យផ្ទៃក្នុងដែលក្រុមប្រឹក្សាភិបាលកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃទៅលើលទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការបង្ហាញប្រសិនបើមានកត្តាដែលពាក់ព័ន្ធនឹងនិរន្តភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែប និរន្តរភាព ប្រសិនបើក្រុមប្រឹក្សាភិបាលមិនមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែធ្វើដូច្នេះ ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាមតិយោបល់របស់សវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែការពារនូវកំហុសឆ្គងជាសារវន្ត នៅពេលដែលវាកើតមានឡើងនោះទេ ។ ភាពខុសឆ្គងដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាកំហុសឆ្គងជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្តុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដែលមានជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសវនកម្ម។ យើងបានធ្វើ៖

- កំណត់ និងការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាតើការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងទទួលខុសត្រូវលើការរៀបចំ និងអនុវត្តតាមនីតិវិធីសវនកម្មអាចឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ដើម្បីទទួលបាននូវភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងជាសារវន្ត ជាលទ្ធផលបណ្តាលមកពីការក្លែងបន្លំច្រើនជាងការភ័ន្តច្រឡំ ការក្លែងបន្លំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬការបំពាននៃការត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលត្រឹមត្រូវទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបង្ហាញមតិយោបល់លើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- វាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន និងកំណត់បង្ហាញពាក់ព័ន្ធដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពគណនេយ្យដែលគណៈគ្រប់គ្រងប្រើប្រាស់ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើជាភាពមិនមានច្បាស់លាស់ជាសារវន្តអាចកើតឡើង ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចសង្ស័យយ៉ាងខ្លាំងលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានជាភាពជាសារវន្តមិនមានច្បាស់លាស់កើតឡើង យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកររងករាជ្យរបស់យើងខ្ញុំ ភ្ជាប់នឹងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបើការបង្ហាញបែបនេះគឺមិនគ្រប់គ្រាន់ នោះមតិយោបល់របស់យើងខ្ញុំនឹងកែប្រែ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនកររងករាជ្យរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឲ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពបាន។
- វាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញទាំងឡាយ រចនាសម្ព័ន្ធ និងមាតិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានកំណត់បង្ហាញព័ត៌មាន ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍នៅក្នុងលក្ខខណ្ឌមួយដែលបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវដែរឬទេ។

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាដទៃទៀតក៏ដូចជា វិសាលភាពដែលបានគ្រោងទុក និងការកំណត់ពេលវេលានៃការធ្វើសវនកម្ម និងការស្វែងរកការធ្វើសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ណាមួយលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលបានកត់សម្គាល់ក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

**បញ្ហាផ្សេងៗ**

របាយការណ៍នេះត្រូវបានធ្វើឡើង សម្រាប់ភាគទុនិករបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវ ចំពោះខ្លឹមសារនៃរបាយការណ៍នេះ សម្រាប់បុគ្គលផ្សេងទៀតឡើយ។




**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃ២៦ ខែមេសា ឆ្នាំ២០២១

## ៥.៣ តារាងតុល្យការ

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

| | កំណត់ | ២០២០ | | ២០១៩ |
|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ១៦.២៥៣ | ៦៥.៧៤៣ | ១៦.០១៦ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ១៧៦.៨៦៨ | ៧១៥.៤៣១ | ១៧៦.០២៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២០៩.៥៦៧ | ៨៤៧.៦៩៨ | ៣៧៩.៧០៧ |
| ឥណទានទៅអតិថិជន | ៩ | ៤.០៥១.២៦៨ | ១៦.៣៨៧.៣៧៩ | ៣.៧២៣.៩៨៤ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ៧៥.០៣៥ | ៣០៣.៥១៧ | ៦១.១៥៩ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១៨២.៩២៧ | ៧៣៩.៩៤០ | ២៣៦.៤៩២ |
| ទ្រព្យសម្បត្តិអរូបី | ១២ | ៤.២៥៨ | ១៧.២២៤ | ៥.៣០៨ |
| **ទ្រព្យសកម្មសរុប** | | ៤.៧១៦.១៧៦ | ១៩.០៧៦.៩៣២ | ៤.៥៩៨.៦៩៥ |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់កម្ចី | ១៣ | ១.០៥២.០៧៧ | ៤.២៥៥.៦៥១ | ៩៧៩.៥៧២ |
| បំណុលពន្ធពន្យា | ១៤ | ៧៤៥ | ៣.០១៤ | ៧៤៥ |
| គណនីត្រូវបង់ផ្សេងៗ | ១៥ | ១៥០.៦៤១ | ៦០៩.៣៤៣ | ៨១.០៨៦ |
| បំណុលពន្ធចរន្ត | | ៦៧១ | ២.៧១៤ | ៦៥៥ |
| **បំណុលសរុប** | | ១.២០៤.១៣៤ | ៤.៨៧០.៧២២ | ១.០៦២.០៥៨ |
| **មូលធន** | | | | |
| ដើមទុន | ១៦ | ៣.៥០០.០០០ | ១៤.១៥៧.៥០០ | ៣.៥០០.០០០ |
| ការផ្តល់ទុនសម្រាប់ការបន្ថែមដើមទុន | ១៧ | ៦០.៨៦១ | ២៤៦.១៨៣ | ១២០.៤២៨ |
| ទុនបម្រុងតាមច្បាប់ | ១៨ | ១៩.៩២៨ | ៨០.៦០៩ | ៣០.៤៣១ |
| ខាតបង្គរ | | (៦៨.៧៤៧) | (២៧៨.០៨២) | (១១៤.២២២) |
| **មូលធនសរុប** | | ៣.៥១២.០៤២ | ១៤.២០៦.២១០ | ៣.៥៣៦.៦៣៧ |
| **បំណុល និងមូលធនសរុប** | | **៤.៧១៦.១៧៦** | **១៩.០៧៦.៩៣២** | **៤.៥៩៨.៦៩៥** |

# ៥.៤ របាយការណ៍លទ្ធផល

**របាយការណ៍លទ្ធផល**

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ គិតជាពាន់រៀល | ២០១៩ ដុល្លារអាមេរិក |
|---|---|---|---|---|
| ចំណូលការប្រាក់ | ១៩ | ៦៣៩.៥៣៦ | ២.៥៨៦.៩២៣ | ៣១៨.៣២៤ |
| ចំណាយការប្រាក់ | ២០ | (៩០.១៤៩) | (៣៦៤.៦៥៣) | (៣៤.៧០២) |
| ចំណូលការប្រាក់សុទ្ធ | | ៥៤៩.៣៨៧ | ២.២២២.២៧០ | ២៨៣.៦២២ |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៩ | (១៦.៧១២) | (៦៧.៦០០) | (៣៧.៧៨៧) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ១៨៧.៧៩១ | ៧៥៩.៦១៥ | ១៨៦.១១៦ |
| ចំណាយប្រាក់បៀវត្ស | ២២ | (៣២៣.៦៧៩) | (១.៣០៩.២៨២) | (២៦៣.៤៦១) |
| ចំណាយរំលស់ | ២៣ | (៦១.៨២០) | (២៥០.០៦២) | (៤៤.៦៧៥) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៤ | (២៩១.៩២៥) | (១.១៨០.៨៣៧) | (១៥៦.៧៤៧) |
| ចំណេញ/(ខាត)មុនបង់ពន្ធ | | ៤៣.០៤២ | ១៧៤.១០៤ | (៣២.៩៣២) |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៥ | (៨.០៧០) | (៣២.៦៤៤) | (៥.៦៣២) |
| ប្រាក់ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ | | ៣៤.៩៧២ | ១៤១.៤៦១ | (៣៨.៥៦៤) |
| ចំណូលផ្សេងៗ បន្ទាប់ពីគិតពន្ធរួច | | - | - | - |
| **ចំណូល/(ខាត)ផ្សេងៗសរុបក្នុងការិយបរិច្ឆេទ** | | **៣៤.៩៧២** | **១៤១.៤៦១** | **(៣៨.៥៦៤)** |

# ៥.៥ របាយការណ៍បម្រែបម្រួលមូលធន

**របាយការណ៍បម្រែបម្រួលមូលធន**

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ការផ្តល់ទុនសម្រាប់ការបន្ថែមដើមទុន ដុល្លារអាមេរិក | ទុនបម្រុងតាមច្បាប់ ដុល្លារអាមេរិក | ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩** | | ១.៥០០.០០០ | - | ២៤.២៣៨ | (៦៩.៤៦៥) | ១.៤៥៤.៧៧៣ |
| លទ្ធផលខាតសរុបក្នុងការិយបរិច្ឆេទ តំណាងដោយ ខាតផ្សេងៗសរុប | | - | - | - | (៣៨.៥៦៤) | (៣៨.៥៦៤) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | |
| ភាគហ៊ុនបោះផ្សាយ | ១៦ | ២.០០០.០០០ | - | - | - | ២.០០០.០០០ |
| ការផ្តល់ទុនសម្រាប់ការបន្ថែមដើមទុន | | - | ១២០.៤២៨ | | | ១២០.៤២៨ |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ | | - | - | ៦.១៩៣ | (៦.១៩៣) | - |
| ប្រតិបត្តិការសរុបជាមួយភាគហ៊ុនិក | | ២.០០០.០០០ | ១២០.៤២៨ | ៦.១៩៣ | (៦.១៩៣) | ២.១២០.៤២៨ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩/ថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | | ៣.៥០០.០០០ | ១២០.៤២៨ | ៣០.៤៣១ | (១១៤.២២២) | ៣.៥៣៦.៦៣៧ |

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ការផ្តល់ទុនសម្រាប់ការបន្ថែមដើមទុន ដុល្លារអាមេរិក | ទុនបម្រុងតាមច្បាប់ ដុល្លារអាមេរិក | ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩/ថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | | **៣.៥០០.០០០** | **១២០.៤២៨** | **៣០.៤៣១** | **(១១៤.២២២)** | **៣.៥៣៦.៦៣៧** |
| លទ្ធផលចំណេញសរុបក្នុងការិយបរិច្ឆេទ តំណាងដោយចំណូលផ្សេងៗសរុប | | - | - | - | ៣៤.៩៧២ | ៣៤.៩៧២ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | |
| ការផ្ទេរចេញពីទុនបម្រុង | | - | - | (១០.៥០៣) | ១០.៥០៣ | - |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | | - | (៥៩.៥៦៧) | - | - | (៥៩.៥៦៧) |
| ប្រតិបត្តិការសរុបជាមួយភាគហ៊ុនិក | | - | (៥៩.៥៦៧) | (១០.៥០៣) | ១០.៥០៣ | (៥៩.៥៦៧) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | | **៣.៥០០.០០០** | **៦០.៨៦១** | **១៩.៩២៨** | **(៦៨.៧៤៧)** | **៣.៥១២.០៤២** |
| *(គិតជាពាន់រៀល)* | | *១៤.១៥៧.៥០០* | *២៤៦.១៨៣* | *៨០.៦០៩* | *(២៧៨.០៨២)* | *១៤.២០៦.២១០* |

# ៥.៦ របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ គិតជាពាន់រៀល | ២០១៩ ដុល្លារអាមេរិក |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | | **៤៣.០៤២** | **១៧៤.១០៤** | **(៣២.៩៣២)** |
| និយ័តកម្ម៖ | | | | |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៩ | ១៦.៧១២ | ៦៧.៦០០ | ៣៧.៧៨៧ |
| រំលស់ទ្រព្យសកម្មអរូបី | ១២ | ១.០៥០ | ៤.២៤៧ | ១.០៥០ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ៦០.៧៧០ | ២៤៥.៨១៥ | ៤៣.៦២៥ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ២០ | (៣.៨៥៣) | (១៥.៥៨៥) | - |
| ចំណាយការប្រាក់ | ១៩ | ៩០.១៤៩ | ៣៦៤.៦៥៣ | ៣៤.៧០២ |
| ចំណូលការប្រាក់ | | (៦៩៦) | (២.៨១៥) | (៨៦៥) |
| ការជម្រះទ្រព្យសម្បត្តិ និងបរិក្ខារចេញពីបញ្ជី | | ២១៤ | ៨៦៦ | ៩១៧ |
| ចំណូលប្រតិបត្តិការមុនពេលបម្រែបម្រួលដើមទុនបង្វិល | | **២០៧.៣៨៨** | **៨៣៨.៨៨៥** | **៨៤.២៨៤** |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | | |
| ឥណទានទៅអតិថិជន | | (៣៤៣.៩៩៦) | (១.៣៨២.១៧៦) | (២.៣៥៨.៩៦៩) |
| គណនីត្រូវទទួលផ្សេងៗ | | ៦៩.៥៥៥ | ២៨១.៣៥០ | (១៨.៣៥០) |
| គណនីត្រូវបង់ផ្សេងៗ | | (១៣.៨៧៦) | (៥៦.១២៨) | ៩.២៥២ |
| សាច់ប្រាក់ប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (៨០.៩២៩) | (៣២៧.៣៥៨) | (២.២៨៣.៧៨៣) |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (៨.០៥៤) | (៣២.៥៧៨) | (៥.២៨៩) |
| ប្រាក់តម្កល់តាមច្បាប់ | | (៩០.១៤៩) | (៣៦៤.៦៥៣) | (១០០.០០០) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | | **(១៧៩.១៣២)** | **(៧២៤.៥៨៩)** | **(២.៣៨៩.០៧២)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ចំណូលការប្រាក់ | | ៦៩៦ | ២.៨១៥ | ៨៦៥ |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៥ | (៨.៥៧៩) | (៣៤.៧០២) | (២៣៩.១៧៣) |
| សាច់ប្រាក់ពីលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៥.០១៣ | ២០.២៧៨ | - |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | **(២.៨៧០)** | **(១១.៦០៩)** | **(២៣៨.៣០៨)** |

**លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន**

| | | | | |
|---|---|---|---|---|
| សាច់ប្រាក់ទទួលបានពីការបោះផ្សាយភាគហ៊ុន | ១៦ | - | - | ២.០០០.០០០ |
| ការដកប្រាក់កម្ចី | | ៧២.៥០៥ | ២៩៣.២៨៣ | ៨៦៩.៥៧២ |
| **ការផ្តល់ទុនសម្រាប់ការបន្ថែមដើមទុន** | | **(៥៩.៥៦៧)** | **(២៤០.៩៤៩)** | **១២០.៤២៨** |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន | | ១២.៩៣៨ | ៥២.៣៣៤ | ២.៩៩០.០០០ |
| **(តំហាយ)/កំណើននៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (១៦៩.០៦៤) | (៦៨៣.៨៦៤) | ៣៦២.៦២០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ៣៩៦.៧៥២ | ១.៦០៤.៨៦១ | ៣៤.១៣២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | **២២៧.៦៨៨** | **៩២០.៩៩៧** | **៣៩៦.៧៥២** |

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ពាន់រៀល | ២០១៩ ដុល្លារអាមេរិក |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៦ | ១៦.២៥៣ | ៦៥.៧៤៣ | ១៦.០១៦ |
| សមតុល្យនៅធនាគារជាតិ (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៧ | ១.៨៦៨ | ៧.៥៥៦ | ១.០២៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២០៩.៥៦៧ | ៨៤៧.៦៩៨ | ៣៧៩.៧០៧ |
| | | **២២៧.៦៨៨** | **៩២០.៩៩៧** | **៣៩៦.៧៥២** |